រដ្ឋ WASHINGTON

DEPARTMENT OF CHILDREN, YOUTH, AND FAMILIES (ក្រសួងកុមារ យុវជន និងក្រុមគ្រួសារ)

1500 Jefferson Street, SE ● P.O. Box 40975 ● Olympia WA 98504-0975

ថ្ងៃទី 8 ខែមិថុនា ឆ្នាំ 2020

លិខិតជូនចំពោះមាតាបិតា

ជាកិច្ចដំបូង ខ្ញុំសូមមានប្រសាសន៍ថាខ្ញុំសង្ឃឹមថាអ្នក និងគ្រួសាររបស់អ្នកមានសុវត្ថិភាព និងសុខភាពល្អនៅពេលអ្នកអានលិខិតនេះ។ សូមអរគុណចំពោះការអត់ធ្មត់ និងការយោគយល់របស់អ្នកដូចដែលយើងបានកែសម្រួលដូចអ្នក ចំពោះការផ្លាស់ប្តូរដ៏ធំនៅក្នុងជីវិតក្នុងអំឡុងពេលប៉ុន្មានខែចុងក្រោយនេះ។ យើងសូមកោតសរសើរចំពោះសុទិដ្ឋិនិយម ភាពបត់បែននិងភាពស៊ូរបស់គ្រួសារក្នុងគ្រាលំបាកទាំងនេះ។ យើងយល់ថា ខណៈពេលដែលអ្នករាល់គ្នាមួយចំនួនបានកោតសរសើរចំពោះការផ្លាស់ប្តូរទៅសេវាកម្មអនឡាញ ការផ្អាកសេវាកម្មផ្ទាល់គឺជាការលំបាកចំពោះអ្នកដទៃ។

ផ្អែកលើផលប៉ះពាល់អំឡុងពេល COVID-19 នៅក្នុងរដ្ឋ Washington និងការព្រួយបារម្ភចំពោះសុខភាពនិងសុខុមាលភាពរបស់កុមារ និងគ្រួសារដែលទទួលបានសេវាកម្ម និងបុគ្គលិកដែលផ្តល់សេវាកម្ម ការិយាល័យរដ្ឋសម្រាប់ការគាំពារដំបូងដល់ទារក និងកុមារតូច (ESIT) បានសម្រេចថា សេវាកម្មផ្ទាល់ដែលកំណត់ការលើកលែងនឹងបន្តផ្អាកជាបណ្តោះអាសន្ន។

យើងបានឮថា អ្នកទាំងអស់គ្នាភាគច្រើនដែលបានផ្លាស់ប្តូរទៅសេវាកម្មអនឡាញបានរីករាយនឹងភាពបត់បែន លទ្ធភាពកាន់តែងាយស្រួលក្នុងការទទួលបានសេវាកម្ម និងការបង្វឹកកាន់តែល្អប្រសើរពីក្រុមអ្នកផ្តល់សេវា។ មានការស្រាវជ្រាវជាច្រើនដែលគាំទ្រដល់ប្រសិទ្ធភាពនៃសេវាកម្មអនឡាញ ហើយវិធីសាស្ត្រនៃការផ្តល់សេវាកម្មនេះនឹងនៅតែជាជម្រើសមួយ។

ប្រសិនបើអ្នកជាឪពុកម្ដាយដែលបានសម្រេចចិត្តរង់ចាំទទួលសេវាកម្មរហូតដល់បានផ្ដល់ដោយផ្ទាល់ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យសាកល្បងសេវាកម្មអនឡាញ។ *យើងសូមធានាថា ពេលវេលាដ៏សំខាន់មិនត្រូវបានបាត់បង់ក្នុងអំឡុងពេលនេះនៃការផ្លាស់ប្ដូរការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅក្នុងជីវិតរបស់កូន។*

យើងក៏ដឹងដែរថាមិនមែនតម្រូវការទាំងអស់អាចត្រូវបានបំពេញបានទេតាមរយៈសេវាកម្មអនឡាញនោះទេ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនីមួយៗរបស់កុមារនិងគ្រួសារទាំង *ទាំងអស់* យើងកំពុងបង្កើតប្រព័ន្ធដើម្បីកំណត់ការលើកលែងសម្រាប់កុមារដែលត្រូវការពេលវេលាសេវាកម្មផ្ទាល់មានដែនកំណត់មុនពេលសេវាកម្មផ្ទាល់ត្រឡប់មកវិញកាន់តែច្រើន។ យើងនឹងធ្វើការសម្រេចចិត្តថាតើសេវាកម្មបែបនេះអាចផ្ដល់ជូននៅកន្លែងណា និងយ៉ាងដូចម្ដេច ដោយធានានូវសុវត្ថិភាពដល់កុមារ ឪពុកម្ដាយនិងបុគ្គលិកដែលផ្ដល់សេវាកម្ម។ ប្រសិនបើអ្នកជឿជាក់ថា កូនរបស់អ្នកកំពុងត្រូវការសេវាកម្មផ្ទាល់ដែលមានដែនកំណត់ សូមទាក់ទងអ្នកផ្ដល់សេវាកម្មរបស់អ្នកដើម្បីពិភាក្សាអំពីពេលវេលាកំណត់ និងជម្រើសដែលអាចមាន។

ដើម្បីគាំទ្រដល់ការធ្វើផែនការសម្រាប់ការវិលត្រឡប់មករកសេវាកម្មផ្ទាល់ ក្រុមការងារតូចមួយដែលមានទាំងអ្នកផ្ដល់សេវាកម្ម និងក្រុមគ្រួសារកំពុងប្រជុំរៀបចំធ្វើផែនការសម្រាប់ ESIT ដែលសមស្របតាមផែនការ Governor Inslee's Safe Start។

គោលដៅសម្រាប់ក្រុមការងារនេះរួមមាន៖

1. ការបង្កើតអនុសាសន៍សម្រាប់ការលើកលែងដែលត្រូវអនុវត្តដែលអាចអនុញ្ញាតឱ្យមួយក្រុមតូចនៃទារកនិងកុមារតូចដែលមានត្រូវការបន្ទាន់ក្នុងរយៈពេលខ្លីដើម្បីទទួលបានការគាំទ្រផ្ទាល់។
2. រៀបចំផែនការផ្លាស់ប្ដូរត្រឡប់ទៅរកសេវាកម្មផ្ទាល់វិញដោយប្រើវិធីសាស្ត្រក្នុងតំបន់ដែលត្រូវអនុវត្តស្របតាមផែនការ Governor Inslee's Safe Start Plan។

ផែនការរបស់យើងនឹងបញ្ចូលមតិយោបល់ពីអ្នកផ្ដល់សេវា ESIT មកពីទូទាំងរដ្ឋហើយសំខាន់បំផុតគឺមកពីគ្រួសារជាច្រើន។

ឆាប់ៗនេះយើងក៏នឹងចែកជូនការស្ទង់មតិគ្រួសារដែលនឹងជួយយើងឱ្យយល់ពីបទពិសោធន៍និងបញ្ហាប្រឈមរបស់ក្រុមគ្រួសារដែលកំពុងទទួលបានសេវាកម្ម ESIT ក្នុងអំឡុងពេលដ៏លំបាកនេះ។

ប្រសិនបើអ្នកមានសំណួរ កង្វល់ ឬគំនិតយោបល់ដែលអ្នកចង់ចែករំលែកជាមួយក្រុមកិច្ចការងារ សូមទាក់ទងខ្ញុំតាម laurie.thomas@dcyf.wa.gov។

យើងសូមថ្លែងអំណរគុណចំពោះការអត់ធ្មត់របស់អ្នកនៅពេលយើងធ្វើការដោះស្រាយបញ្ហានេះជាមួយគ្នា ។

ដោយក្តីស្មោះត្រង់

Laurie Thomas
រដ្ឋបាល
កម្មវិធីការគាំពារដំបូងដល់ទារកនិងកុមារតូច (ESIT)